- ប្រមូលផ្តុំ និង លើកគំរោងអភិវឌ្ឍន៍គ្រប់ផ្នែកក្នុងវិស័យកសិកម្មសំរាប់អាស៊ាន ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និង សំរេច ។
- សហការ និង សំរបសំរួលជាមួយអង្គភាពពាក់ព័ន្ធ អនុវត្តកិច្ចការអាស៊ាននៅក្នុងក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ អោយដំណើរការបានល្អស្របតាមកិច្ចការអភិវឌ្ឍន៍របស់ សមាគមអាស៊ាន ។

**មាត្រា ៣ :** ក្របខ័ណ្ឌមន្រ្តីរាជការ របស់ការិយាល័យអាស៊ានកសិកម្ម អាស្រ័យដោយនាយកដ្ឋានផែនការ និង សហប្រតិបត្តិការកំណត់សំរេច ។

**មាត្រា ៤ :** ការិយាល័យអាស៊ានកសិកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជំនួយការ ។

**មាត្រា ៥ :** អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការ និង សហប្រតិបត្តិការ ព្រមទាំងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**តាវ សេងហួរ**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៦

## ប្រកាស លេខ : ៣៦០ ប្រក.កសក.ចន

## ស្តីពីការរំសាយអង្គភាព

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ១៩៩៤ ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញប្រកាសលេខ ៤១១ ប្រក.កសក.ចត ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានក្សេត្រសាស្ត្រ
- តាមសំណើរបស់នាយកដ្ឋានក្សេត្រសាស្ត្រ

**សំរេច**

**មាត្រា ១ :** ត្រូវបានរំសាយស្ថានីយ៍ពិសោធន៍ស្រាវជ្រាវពូជថ្នាំជក់សំរោងធំ ចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៦ ចេញពីរសម្ព័ន្ធចាត់តាំងរបស់នាយកដ្ឋានក្សេត្រសាស្ត្រ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ២ :** មន្ត្រី បុគ្គលិក កម្មករ របស់ស្ថានីយ៍នេះ ដែលស្ម័គ្រចិត្តសុំលាឈប់ និង និងសុំមកបំរើការងារនៅ នាយកដ្ឋានក្សេត្រសាស្ត្រ ត្រូវកំណត់តាមប្រកាសដោយឡែក ។

**មាត្រា ៣ :** សេចក្តីសំរេចណា ដែលពាក់ព័ន្ធនឹងស្ថានីយ៍ពិសោធន៍ស្រាវជ្រាវពូជថ្នាំជក់សំរោងធំ ហើយមានខ្លឹម សារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ–ហិរញ្ញវត្ថុ និង ប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ។ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**តាវ សេងហួរ**

* * *